ព្រះរាជាណាចក្រកម្ពុជា

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំចក្រភពអង់គ្លេស

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ

ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅចក្រភពអង់គ្លេស មានកិត្តិយសសូមជម្រាបជូនថា នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ខាងមុខ គឺជាថ្ងៃដែលប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេស ប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** គម្រប់ខួប **៩ឆ្នាំ**។

អាស្រ័យហេតុនេះ ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅចក្រភពអង់គ្លេស នឹងរៀបចំប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** គម្រប់ខួប **៩ឆ្នាំ** នៅថ្ងៃទី **១៥ ខែតុលា ឆ្នាំ២០២១** វេលាម៉ោង **១១:០០ព្រឹក** នៅស្ថានទូតកម្ពុជាប្រចាំចក្រភពអង់គ្លេស អាសយដ្ឋាន៖ 64 Brondesbury Park, Willesden Green, NW6 7AT, London, United Kingdom។

សេចក្តីដូចបានជម្រាបជូនខាងលើ ស្ថានឯកអគ្គរាជទូត សូមគោរពអញ្ជើញបងប្អូនប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅចក្រភពអង់គ្លេស ចូលរួមពិធីគោរពព្រះវិញ្ញាណក្ខន្ធនេះ និងសូមចុះឈ្មោះចូលរួមតាមរយៈ Link៖ https://docs.google.com/forms/d/e/1FAIpQLSfE5494wjo2GqJzdlfuTs9OpsoeuMzoJ0FSCCVGR2NkgRJYjg/viewform?usp=sf_link ឱ្យបានមុន**ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១**។

សូមអរគុណ!

ថ្ងៃពុធ ១៥រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
ទីក្រុងឡុងដ៍, ថ្ងៃទី០៦ ខែតុលា ឆ្នាំ ២០២១

ព្រះរាជាណាចក្រកម្ពុជា
ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅចក្រភពអង់គ្លេស

64 Brondesbury Park, Willesden Green, London NW6 7AT, Tel: +44 20 8451 7850, Fax: +44 20 8451 7594
Email: cambodianembassy@btconnect.com Website: www.cambodianembassy.org.uk